ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១០០/០៩-យ៉ុង វ៉ា ហោគគក់
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: សេង រ័ត្នហ៊ុន
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: ទូច ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: ប៉ែន រ៉ូឌណា

## គូភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ លីមីធីត
អាសយដ្ឋាន : ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទ : ០១៦ ៥៨៤ ៥០៥ ទូរសារ : គ្មាន
តំណាងភាគីនិយោជក :

| | |
|---|---|
| ១- កញ្ញា Tgh Siqi Annabel | Ex Manager |
| ២- លោក ភ័ន បូរ៉ា | ជំនួយការរដ្ឋបាល |
| ៣- លោក ភាម ចាន់ | Executive Personal/HR |
| ៤- លោក Pen Suthea | Staff |
| ៥- លោក គោល ស៊ីរ៉េតី | H/R Yung Wah I & I. |
| ៦- លោក Ng Min Chuan | H/R Yung Wah I & II |
| ៧- លោក Tho Sophea | H/R Yung Wah I & II |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : ~ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)

~ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ យ៉ុង វ៉ា ២

អាសយដ្ឋាន : ផ្ទះលេខ ៦ សេ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៥៨៨ ៦២៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោកស្រី ហាស វណ្ណី | មន្ត្រី C.CAWDU |
| ២- លោក រិរម សុភ័ក្ត្រា | មន្ត្រី C.CAWDU |
| ៣- លោកស្រី សុខ ផល្លា | ប្រធានសហជីពស៊ីខៅឌូ ប្រចាំរោងចក្រ យ៉ុង វ៉ា ២ |
| ៤- លោកស្រី ចាន់ ដានី | អនុប្រធានសហជីព |
| ៥- កញ្ញា កែវ សម្ផស្ស | លេខាធិការសហជីព |
| ៦- លោក ម៉ឺន ប៉ន | កម្មករ |
| ៧- លោក ខួង ប៊ុនធឿន | កម្មករ |
| ៨- លោក ឆេក សុខនី | កម្មករ |
| ៩- លោក ជួន សុផន | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករស្នើឱ្យទទួលខុសត្រូវចំពោះបុគ្គលិក ២ នាក់ ដែលបានបើកឡានបុកកម្មករចំនួន ២ នាក់ ( អត្តលេខ ៩៤៥១ និងអត្តលេខ ៩៥៦១ ) បណ្តាលឱ្យមានរបួស នូវជំងឺចិត្តក្នុងម្នាក់ ៥០០ ដុល្លារ ។ ក្រុមហ៊ុនមិនឯកភាព ។

២- កម្មករសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ក្នុងកំឡុងពេលកម្មករធ្វើកូដកម្ម ។ ក្រុមហ៊ុនមិនឯកភាព គឺអនុវត្តតាមច្បាប់ស្តីពីការងារ ។

៣- កម្មករស្នើមិនឱ្យក្រុមហ៊ុនធ្វើការគំរាមដល់កម្មករដែលបានចូលរួមធ្វើកូដកម្ម ។ ក្រុមហ៊ុនមិនបានគំរាមដល់កម្មករបានចូលរួមធ្វើកូដកម្មទេ ។

៤- កម្មករស្នើឱ្យក្រុមហ៊ុនពិនិត្យលើដំណើរការបញ្ឈប់កម្មកររួមលើតំណែងមួយចំនួន ដូចជា:

- ការផ្តល់ប្រាក់ខែគោល ជូនដំណឹងមុនតាមច្បាប់ស្តីពីការងារ មាត្រា ៧៥

- ការផ្តល់ប្រាក់ជាមធ្យមចំពោះប្រាក់ជូនដំណឹង និងបណ្តេញចេញមាត្រា ៨៩ និងមាត្រា ៩១ តាមច្បាប់ស្តីពីការងារ ។

- ការពិនិត្យលើមូលហេតុនៃការបញ្ឈប់ការងាររួម និងធ្វើកិច្ចព្រមព្រៀងក្នុងការផ្តល់អាទិភាព ឱ្យជ្រើសរើសចូលធ្វើការវិញ ។

ក្រុមហ៊ុនឯកភាពគិតប្រាក់ឈ្នួលតាមច្បាប់ចំនួន៥ចំណុច ជូនកម្មករណាមិនមានកំហុស និងគិតប្រាក់ឈ្នួល ជូនចំពោះកម្មករណាមានកំហុសចំនួន២ចំណុច គឺប្រាក់ឈ្នួលចុងក្រោយ និងប្រាក់បំណាច់ជួសការឈប់សម្រាក ប្រចាំឆ្នាំ។ ក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការជ្រើសរើសកម្មករថ្មីចូលធ្វើការ ពីព្រោះក្រុមហ៊ុនបានអាជ្ញាប័ណ្ណថ្មី (License ថ្មី ) ។

៥- កម្មករស្នើសុំក្រុមហ៊ុនបញ្ឈប់ជាបន្ទាន់ ចំពោះការបញ្ចប់កិច្ចសន្យាស្ងាត់ៗ ទិញទឹកចិត្ត និងធ្វើទុកបុក ម្នេញមកលើសកម្មភាពសហជីព ។ ក្រុមហ៊ុនមិនបានបញ្ចប់កិច្ចសន្យាស្ងាត់ៗ ទិញទឹកចិត្ត និងធ្វើទុកបុកម្នេញមក លើសកម្មភាពសហជីពទេ ។

៦- ស្នើឱ្យក្រុមហ៊ុនផ្តល់សេរីភាពសហជីពឱ្យបានពេញលេញដល់សហជីព ស៊ីខៅឌូ នៅក្នុងរោងចក្រក្នុង ការធ្វើការងារសហជីព។ ក្រុមហ៊ុននឹងផ្តល់សេរីភាពសហជីពឱ្យបានពេញលេញ ដល់សហជីព ស៊ីខៅឌូ នៅក្នុងរោង ចក្រក្នុងការធ្វើការងារសហជីព ។

៧- រាល់ការរៀបចំ និងចាត់ចែងផ្សេងៗទៅលើកម្មករត្រូវពិភាក្សាជាមួយសហជីព ស៊ីខៅឌូ ជាមុន។ ក្រុមហ៊ុនឯកភាពចំពោះរាល់ការរៀបចំ និងចាត់ចែងផ្សេងៗ ទៅលើកម្មករត្រូវពិភាក្សាជាមួយសហជីព ស៊ីខៅឌូ ជាមុន ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីសម្រេចនេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាមួយគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ២៨៩/០៩ ក.ប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩ ( វេលាម៉ោង ០៨:០០ នាទី ព្រឹក) ។

បញ្ហានៃនីតិវិធី :

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន៨ចំណុច ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន០១ចំណុច និងមិនសះជានឹងគ្នាចំនួន០៧ចំណុច ។ ចំណុចមិនសះជាទាំង០៧ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២៨៩/០៩ កប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំងនេះ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជាទាំង០៧ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នានូវចំណុចវិវាទទី៦ និងភាគីកម្មករនិយោជិតបានយល់ព្រមដកចំណុចវិវាទទី២ ទី៣ ទី៤ ទី៥ និងទី៧ ចេញពីការទាមទារ ។ ដូច្នេះ ចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ក្រុមហ៊ុន យ៉ុង វ៉ា ទី២ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ។

២- សារណាសង្ខេបនៃវិវាទការងារ ។

៣- កំណត់ហេតុប្រជុំស្តីពីការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាសស្ទ្រៀល លេខ ៩៨១ ពណ.នគក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៨ ។

៥- អនុស្សរណៈ និង លក្ខន្តិកៈ ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាសស្ទ្រៀល ទី២ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ។

៧- រូបថតចំនួន ១៥ សន្លឹក ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ យ៉ុង វ៉ា ២ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ។

២- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ យ៉ុង វ៉ា ២ លេខ ១២២៦ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨ ។

៣- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមកអ្នកស្រីប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ យ៉ុង វ៉ា ២ លេខ ៣០២ កប/អក/វក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ។

៤- សារណាសង្ខេបលើសំណុំរឿងនៅរោងចក្រ យ៉ុង វ៉ា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ។

៥- ពាក្យបណ្តឹងរបស់កម្មករឈ្មោះ ចេក សុខនី ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ។

៦- ពាក្យបណ្តឹងរបស់កម្មករឈ្មោះ ជួន សុផន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ុង វ៉ា លេខ ២៨៥/០៩ កប/កណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ុង វ៉ា ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៤៩៨ កប/អក/វក/លកអ. ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៩៩ កប/អក/វក/លកអ. ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

សំអាងហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់សំណេះសំណាលរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន យ៉ុង វ៉ា បោកគក់ (យ៉ុងវ៉ា ២) មានជួលកម្មករនិយោជិតសរុបចំនួនប្រហែល ៥០០០នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ យ៉ុងវ៉ា ២ ជាភាគីដើមបណ្តឹងក្នុងសំណុំរឿងនេះ។

ចំណុចវិវាទទី១ ៖ កម្មករនិយោជិតឈ្មោះ ចេក សុខនី និង ជួន សុផន ទាមទារឱ្យក្រុមហ៊ុន សងថ្លៃព្យាបាល និងជម្ងឺចិត្តម្នាក់ៗ ចំនួន ៥០០ ដុល្លារអាមេរិក ពីព្រោះបុគ្គលិកអ្នកបើកបរបានបើកឡានកិនជើងពួកគាត់

- ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ កម្មករនិយោជិតបាននាំគ្នាធ្វើកូដកម្មនៅខាងមុខរោងចក្រ ទាមទារឱ្យក្រុមហ៊ុន ឱ្យកម្មករនិយោជិតបោកគក់ចំនួន៤៥នាក់ ក្នុងចំណោមកម្មករនិយោជិតបោកគក់ចំនួន១៣០នាក់ ដែលក្រុមហ៊ុនប្តូរឱ្យទៅធ្វើការវេនយប់មកធ្វើការនៅវេនថ្ងៃវិញ។ កម្មករនិយោជិតបាននាំគ្នាធ្វើកូដកម្ម ដោយមិនមានការជូនដំណឹងមុន ដល់ក្រុមហ៊ុន និងមិនបានគោរពតាមនីតិវិធីបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ០៩:០០ នាទីព្រឹក បុគ្គលិកអ្នកបើកបរឈ្មោះ គន់ ចាន់ធឿន និងបុគ្គលិកម្នាក់ទៀតអង្គុយក្បែរអ្នកបើកបរនោះបានបើកឡានទំងន់ ២,៥ តោន ចេញពីខ្លោងទ្វាររោងចក្រយ៉ាងលឿន ក្នុងរំឡុងពេលកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឈរនៅខាងមុខខ្លោងទ្វាររោងចក្រ បណ្តាលឱ្យកិនប្រអប់ជើងខាងឆ្វេងកម្មករនិយោជិតឈ្មោះ ចេក សុខនី បណ្តាលឱ្យគ្រេច ហើយហើម និងកម្មករនិយោជិតឈ្មោះ ជួន សុផន បណ្តាលឱ្យមានរបួសជើងខាងឆ្វេង ពីមេជើងខ្ទាំដល់ក្រចក។ តំណាងសហជីព បាននាំលោក ចេក សុខនី ទៅពេទ្យឯកជន លឹម សេង ហើយគ្រូពេទ្យបានបង្គាប់ឱ្យផ្សំថ្នាំយកទៅលេប។ ប៉ុន្តែដោយសារតែលោក ចេក សុខនី មិនមានប្រាក់ សហជីពក៏បានយកប្រេងកូឡាហោប និងយកបង់មករុំជើងឱ្យគាត់រស់ប្រាក់ចំនួនប្រហែល ៥០០០ រៀល។ ចំណែកឯលោក ជួន សុផន វិញ សហជីពមិនបាននាំគាត់ទៅពេទ្យទេ គឺមានអង្គការលីកាដូ បានឱ្យថ្នាំគាត់មួយបន្ទះលេប។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា លោក គន់ ចាន់ធឿន ជាអ្នកបើកបរថយន្តឱ្យថៅកែរោងចក្រ។ នៅថ្ងៃកើតហេតុនេះ គាត់បានបើកឡានទម្ងន់ ២,៥ តោននេះ។ ភាគីក្រុមហ៊ុនបញ្ជាក់ថា លោក គន់ ចាន់ធឿន ពិតជាអ្នកបើកបរឱ្យថៅកែរោងចក្រមែន ប៉ុន្តែគាត់ក៏អាចបើកឡានប្រភេទផ្សេងៗដែរ ក្នុងករណីចាំបាច់។

- លោក ចេក សុខនី បានបញ្ជាក់ថា គាត់បានឈប់សម្រាកនៅផ្ទះ ដើម្បីព្យាបាលអស់រយៈពេលជាងមួយខែ។ ប៉ុន្តែ លោក ចេក សុខនី មិនបានបញ្ជាក់ថា គាត់បានចំណាយលើថ្លៃព្យាបាលអស់ប្រាក់ប៉ុន្មានទេ។
- លោក ជួន សុផន បានបញ្ជាក់ថា មេជើងរបស់គាត់បានខ្ទាំដល់ក្រចក បានហើមជាងមួយខែដែរ។ ប៉ុន្តែគាត់មិនបានឈប់សម្រាកនៅផ្ទះទេ គឺគាត់នៅធ្វើការរហូត ដោយដើរញ៉ាំងខ្ញើចៗ ហើយបានឱ្យគ្រូពេទ្យមកចាក់ថ្នាំនៅផ្ទះកន្លះខែអស់ប្រាក់ប្រហែល៣០០ដុល្លារអាមេរិក។ ប៉ុន្តែ មិនមានវិក្កយប័ត្របញ្ជាក់ការចំណាយលើថ្លៃព្យាបាលផ្តល់ជូនក្រុមហ៊ុនទេ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា កម្មករនិយោជិតមិនបានមកប្រាប់ និងស្នើសុំឱ្យក្រុមហ៊ុននាំកម្មករនិយោជិត ដែលរងគ្រោះថ្នាក់ទៅពេទ្យទេ។ ហេតុនេះ ក្រុមហ៊ុនមិនបានដឹងទេ។ ប្រសិនបើកម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុននាំទៅពេទ្យ នោះក្រុមហ៊ុននឹងរ៉ាប់រងរាល់ការចំណាយផ្សេងៗ។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅពេលមានគ្រោះថ្នាក់នោះ គឺរដ្ឋបាលចាស់ លោក ចាន់ មេរិទ្ធិ ហៅ រត្ន័ បានដឹង ប៉ុន្តែ ឥឡូវនេះ គាត់បានឈប់ពីការងារហើយ ហើយរដ្ឋបាលថ្មីមកធ្វើរដ្ឋបាលជំនួសវិញ។ ដូច្នេះ ពេលសហជីពបានជម្រាបប្រាប់រដ្ឋបាលថ្មី ជាដំបូង គាត់បានបដិសេធថា មិនមានគ្រោះថ្នាក់ទេ ប្រសិនបើមានគ្រោះថ្នាក់គិនជើងកម្មករនិយោជិតមែននោះ គឺបែកជើងអស់ទៅហើយ ពីព្រោះ ឡានមានទម្ងន់ ២,៥ តោន។ ប៉ុន្តែ បន្ទាប់ពីមានការសម្របសម្រួល និងនាំលោក ចេក សុខនី មកជួប ទើបក្រុមហ៊ុនទទួលស្គាល់ថា មានគ្រោះថ្នាក់ ហើយបានអនុញ្ញាតឱ្យលោក ចេក សុខនី ឈប់សម្រាករយៈពេល ០៣ ថ្ងៃ ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា មានតែលោក ចេក សុខនី ទេ បានមកជួបក្រុមហ៊ុន ហើយក្រុមហ៊ុនបានអនុញ្ញាតឱ្យគាត់ ឈប់សម្រាករយៈពេលបីថ្ងៃ ដូចកម្មករនិយោជិតបានលើកឡើង។
- ភាគីក្រុមហ៊ុនបានបញ្ជាក់បន្ថែមថា កម្មករនិយោជិតមិនបានផ្តល់វិក្កយប័ត្រចំណាយលើការព្យាបាលផ្សេងៗ ជូនក្រុមហ៊ុនទេ។ ហេតុនេះ ក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារបានទេ។ ប៉ុន្តែ ក្រុមហ៊ុននឹងចេញថ្លៃចំណាយព្យាបាលផ្សេងៗ ប្រសិនបើកម្មករនិយោជិតបានផ្តល់វិក្កយប័ត្រចំណាយផ្សេងៗ បញ្ជាក់ឱ្យបានច្បាស់លាស់ជូនក្រុមហ៊ុន។ ភាគីកម្មករនិយោជិតទទួលស្គាល់ថា កម្មករនិយោជិតមិនបានផ្តល់វិក័យប័ត្រចំណាយលើការព្យាបាលផ្សេងៗ ជូនក្រុមហ៊ុនទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិត ផ្តល់វិក័យប័ត្រចំណាយលើការព្យាបាលផ្សេងៗ របស់លោក ចេក សុខនី និងលោក ជួន សុផន ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានដាក់ឯកសារតាមកាលកំណត់ទេ។

THE ARBITRATION COUNCIL

- ភាគីកម្មករនិយោជិតបានបញ្ជាក់ផងដែរថា បន្ទាប់ពីភាគីកម្មករនិយោជិត បានដាក់ពាក្យបណ្តឹងទៅប៉ូលីស នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ មក ប៉ូលីសបានកោះប្រជុំជាមួយភាគីក្រុមហ៊ុន ជាមួយភាគីកម្មករនិយោជិត ជាបន្តបន្ទាប់ ហើយចុងក្រោយ ប៉ូលីសបានបញ្ជាក់ថា ក្រុមហ៊ុនឯកភាពផ្តល់ជូនចំនួន ១៥០ ដុល្លារអាមេរិក ដល់កម្មករនិយោជិតទាំងពីរនាក់ ប៉ុន្តែ កម្មករនិយោជិតមិនព្រម ។ ភាគីក្រុមហ៊ុនជំទាស់ ដោយបញ្ជាក់ថា ក្រុមហ៊ុនមិនដែលបានឯកភាពផ្តល់នូវចំនួនទឹកប្រាក់ណាមួយនោះទេ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ឥឡូវនេះ ប៉ូលីសក៏បានធ្វើកំណត់ហេតុប្តឹងទៅតុលាការរួចហើយដែរ លើករណីគ្រោះថ្នាក់ដែលកើតឡើងលើកម្មករនិយោជិតពីរនាក់នេះ ។ ភាគីកម្មករនិយោជិតបានសន្យាផ្តល់កំណត់ហេតុ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានដាក់កំណត់ហេតុតាមកាលកំណត់ទេ ។
- នៅក្នុងរបាយការណ៍មិនសះជា កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងជម្ងឺចិត្តនូវទឹកប្រាក់ ៥០០ ដុល្លារអាមេរិក ក្នុងកម្មករនិយោជិតម្នាក់ ប៉ុន្តែ នៅក្នុងសវនាការភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរចុងក្រោយ ទាមទារឱ្យក្រុមហ៊ុនសងថ្លៃព្យាបាល និងជម្ងឺចិត្ត ក្នុងម្នាក់១ ៣០០ ដុល្លារអាមេរិក ។ ប៉ុន្តែ ភាគីក្រុមហ៊ុននៅតែប្រកាន់ជំហរថា មិនអាចផ្តល់ជូនតាមការទាមទារបានទេ ។

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទទី១:** កម្មករនិយោជិត ឈ្មោះ ចេក សុខនី និង ជួន សុផន ទាមទារឱ្យក្រុមហ៊ុន សងថ្លៃព្យាបាល និងជម្ងឺចិត្ត ម្នាក់១ចំនួន ៥០០ ដុល្លារអាមេរិក ពីព្រោះ បុគ្គលិកអ្នកបើកបរបានបើកឡានកិនជើងពួកគាត់

ភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរចុងក្រោយនៃការទាមទាររបស់គាត់ គឺទាមទារឱ្យក្រុមហ៊ុនសងថ្លៃព្យាបាល និងជម្ងឺចិត្ត ម្នាក់១ ចំនួន ៣០០ ដុល្លារអាមេរិក ពីព្រោះ បុគ្គលិកអ្នកបើកបរបានបើកឡានកិនជើងពួកគាត់ ហើយគ្រោះថ្នាក់នេះកើតឡើងនៅពេលពួកគាត់កំពុងធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទទួលបានថ្លៃព្យាបាល និងជម្ងឺចិត្ត ម្នាក់១ ចំនួន ៣០០ ដុល្លារអាមេរិក ឬទេ?

មាត្រា ២៤៨ នៃច្បាប់ស្តីពីការងារ ចែងថា *"ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬ ក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ បើទោះមានកំហុសមកពីកម្មករនិយោជិតឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬ នាយកសហគ្រាស ឬ ធ្លាក់លើកិច្ចវិជ្ជាជីវៈ មានលក្ខណៈ ឥតលក្ខណៈ កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ...* ។

*ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិត ក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅដ្ឋានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬ ដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ក្រៅពីការងារដែលគេតំរូវឱ្យទៅ ។*

*ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ ដូចមានបញ្ជាក់ក្នុងច្បាប់ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលការជួសជុលដូចគ្នាដែរ ។"*

តាមខ្លឹមសារនៃមាត្រា ២៤៨ ខាងលើនេះ គ្រោះថ្នាក់ការងារអាចកើតមានឡើង មានបីករណី គឺទី (១) គ្រោះថ្នាក់ដែលកើតឡើង ដោយសារការបំពេញការងារ ឬ នៅក្នុងម៉ោងធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬ គ្មានក៏ដោយ ទី (២) គ្រោះថ្នាក់ដែលកើតឡើង នៅពេលដែលកម្មករនិយោជិតធ្វើដំណើរពីលំនៅដ្ឋានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬ ដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ក្រៅពីការងារដែលគេតំរូវឱ្យទៅ និងទី (៣) ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ ។

មាត្រា ២៤៩ នៃច្បាប់ស្តីពីការងារចែងថា " *នាយកសហគ្រាសត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់ ដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ទោះបីលក្ខន្តិកៈផ្ទាល់ខ្លួនរបស់កម្មករនិយោជិតម្នាក់ៗនោះ មានលក្ខណៈយ៉ាងណាក៏ដោយ ។"*

ផ្អែកលើខ្លឹមសារ នៃមាត្រា ២៤៩ នៃច្បាប់ស្តីពីការងារខាងលើ និយោជកមានកាតព្វកិច្ច ទទួលខុសត្រូវចំពោះគ្រោះថ្នាក់ការងារដែលកើតលើកម្មករនិយោជិត ឬសិស្សវិជ្ជាជីវៈដែលធ្វើការនៅក្នុងក្រុមហ៊ុន ឬសហគ្រាស (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿង *លេខ ២៣/០៧-យូ មីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២* ) ។ មានន័យថា ប្រសិនបើមានគ្រោះថ្នាក់ការងារ ជនរងគ្រោះនៃគ្រោះថ្នាក់ការងារ គឺមានសិទ្ធិទទួលបាននូវសំណងសម្រាប់ការព្យាបាល ។ ជនរងគ្រោះ គឺមានសិទ្ធិទទួលបាននូវសិទ្ធិទាំងនេះ ដោយមិនគិតពីមូលហេតុនៃគ្រោះថ្នាក់ការងារ ហើយមិនមិនគិតថា នរណាជាអ្នកខុសនោះទេ ។ មានន័យថា បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលចែងអំពីគ្រោះថ្នាក់ការងារ គឺមិនបាននិយាយអំពីកំហុសរបស់ភាគីទេ ទោះបីជាកំហុសចេតនាក្តី ឬ កំហុសដោយការធ្វេសប្រហែសក្តី ។ បទប្បញ្ញត្តិនៃច្បាប់ស្តីការងារ ដែលចែងអំពីគ្រោះថ្នាក់ការងារ គឺកំណត់តែគ្រោះថ្នាក់ការងារដែលកើតលើកម្មករនិយោជិត ឬ សិស្សវិជ្ជាជីវៈ ដែលធ្វើការនៅក្នុងក្រុមហ៊ុន ឬ សហគ្រាសតែប៉ុណ្ណោះ ។

ក្នុងករណីនេះ កម្មករនិយោជិត ឈ្មោះ ចេក សុខនី និងកម្មករនិយោជិត ឈ្មោះ ជួន សុផន បានទទួលគ្រោះថ្នាក់ឡានកិនជើង ដែលបណ្តាលមកពីបុគ្គលិកអ្នកបើកបរឈ្មោះ គន់ ចាន់ធឿន បានបើកឡានទំងន់ ២,៥ តោន ចេញពីខ្លោងទ្វាររោងចក្រ នៅពេលកូដកម្មនៅមុខខ្លោងទ្វាររោងចក្រ នៅថ្ងៃកូដកម្ម ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ០៩:០០ នាទី ព្រឹក ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គ្រោះថ្នាក់នេះ ជាគ្រោះថ្នាក់ដែលកើតមាននៅពេលកំឡុងពេលធ្វើកូដកម្ម ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើ

គ្រោះថ្នាក់ដែលកើតមាននៅពេលធ្វើកូដកម្ម គឺជាគ្រោះថ្នាក់ដែលកើតឡើងដោយសារការបំពេញការងារ ឬនៅក្នុងម៉ោងធ្វើការ ដែរ ឬទេ?

ជាទូទៅ បទប្បញ្ញត្តិដែលទាក់ទងនឹងគ្រោះថ្នាក់ការងារនេះ គឺជាគ្រោះថ្នាក់ដែលកើតឡើងនៅក្នុងទំនាក់ទំនងការងាររវាងនិយោជក និងកម្មករនិយោជិត ។ មានន័យថា គ្រោះថ្នាក់ដែលកើតឡើងនៅក្នុងពេលប្រតិបត្តិកិច្ចសន្យាការងារ ហើយគ្រោះថ្នាក់កើតឡើងដោយសារការងារ ឬ នៅក្នុងម៉ោងការងារ ។

ចំពោះគ្រោះថ្នាក់ដែលកើតមាននៅពេលធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើជាគ្រោះថ្នាក់ការងារ ឬ ទេ?

មាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ ចែងថា: " *កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម ។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់អោយទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកអោយដែរ ។...*"

តាមមាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ នេះមានន័យថា កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម ។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ ។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនយល់ឃើញថា គ្រោះថ្នាក់ដែលកើតមាននៅអំឡុងពេលកម្មករនិយោជិតធ្វើកូដកម្ម មិនមែនជាគ្រោះថ្នាក់ការងារទេ ។ ពីព្រោះ នៅក្នុងអំឡុងពេលធ្វើកូដកម្ម កម្មករនិយោជិតមិនធ្វើការឱ្យនិយោជកទេ មានន័យថា នៅពេលកូដកម្មកិច្ចសន្យាការងារត្រូវបានព្យួរ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿង *លេខ ៨៥/០៧-វីវ៉ាទីណូ ឌីហ្សាញ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១* ) ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គ្រោះថ្នាក់កើតឡើងលើលោក ចេក សុខនី និងលោក ជួន សុផន នៅពេលកម្មករនិយោជិតធ្វើកូដកម្ម ហើយលោក ចេក សុខនី និងលោក ជួន សុផន មិនបានធ្វើការទេ ទោះបីជាច្បាប់បានផ្តល់សិទ្ធិឱ្យពួកគេធ្វើកូដកម្មក៏ដោយ ក៏គ្រោះថ្នាក់ដែលកើតលើអ្នកទាំងពីរ មិនមែនជាគ្រោះថ្នាក់ការងារដែរ តាមមាត្រា ២៤៨ និងមាត្រា ៣២២ នៃច្បាប់ស្តីពីការងារ ។ ហើយបើគ្រោះថ្នាក់នោះ មិនមែនជាគ្រោះថ្នាក់ការងារ ច្បាប់ស្តីពីការងារ ក៏មិនបានបង្គាប់ឱ្យនិយោជកផ្តល់នូវសំណងសម្រាប់ការព្យាបាលដែលមិនមែនជាគ្រោះថ្នាក់ការងារនោះទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនសងជំងឺចិត្តជូនលោក ចេក សុខនី និងលោក ជួន សុផន ក្នុងម្នាក់ៗ ចំនួន ៣០០ ដុល្លារអាមេរិក ។ ការបដិសេធរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មិនរារាំងដល់លោក ចេក សុខនី និងលោក ជួន សុផន ក្នុងការរកដំណោះស្រាយតាមមធ្យោបាយស្របច្បាប់ផ្សេងទៀតទេ ហើយក៏មិនរារាំងនិយោជក ក្នុងការការពារតទល់ប្រឆាំងនឹងបណ្តឹងនោះដែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា ព្រឹត្តិការណ៍គ្រោះថ្នាក់ដែលកើតលើលោក ចេក សុខនី និង

លោក ជួន សុផន ដែលប៉ះពាល់ដល់សុខភាព និងសុវត្ថិភាព គឺជាព្រឹត្តិការណ៍ដ៏អាក្រក់មួយ ដែលមិនគួរណាកើតមានទេ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផល ដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ:

## សម្រេច និង បង្គាប់

ចំណុចវិវាទទី១: បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនសងថ្លៃព្យាបាល និងជម្ងឺចិត្ត ជូនលោក ចេក សុខនី និងលោក ជួន សុផន ក្នុងម្នាក់ៗ ចំនួនទឹកប្រាក់ ៣០០ ដុល្លារអាមេរិក។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេង ឡុចហ៊ុន**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈរ**

ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL